## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា

xxxxxxxxxxxxxxxxxx

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១. –**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលហៅកាត់ថា គ.ក.ប ។

**មាត្រា ២. –**

អនុក្រឹត្យនេះ មានគោលបំណង ជំរុញ ធានានូវគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិតែមួយ និងពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ ផ្សព្វផ្សាយ និង អនុវត្តច្បាប់ និង បទប្បញ្ញត្តិកម្មសិទ្ធិបញ្ញានានាឱ្យមានភាពរលូន ស្របតាមការសន្យា របស់ព្រះរាជាណាចក្រកម្ពុជា នៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងសហការទទួល និង ប្រើប្រាស់ជំនួយ បច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ពីអង្គការអន្តរជាតិ និង ប្រទេសនានា ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី ២

## សមាសភាព និង ភារកិច្ច

**មាត្រា ៣. –**

គ.ក.ប មានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| - រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | អនុប្រធាន |
| - តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| - តំណាង ក្រសួងព័ត៌មាន | សមាជិក |
| - តំណាង ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ | សមាជិក |
| - តំណាង ក្រសួងសុខាភិបាល | សមាជិក |
| - តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| - តំណាង ក្រសួង បរិស្ថាន | សមាជិក |

៤

- តំណាង ក្រសួងយុត្តិធម៌ សមាជិក
- តំណាង ក្រសួងអប់រំ យុវជន និង កីឡា សមាជិក
- តំណាង ក្រសួងទេសចរណ៍ សមាជិក

**មាត្រា ៤. –**

គ.ក.ប មានភារកិច្ចដូចតទៅ ÷

- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការ ទ្វេភាគី ឬពហុភាគី លើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស និង អង្គការអន្តរជាតិនានា
- សម្របសម្រួលឱ្យមានភាពរលូនលើរាល់ការងារ ដែលទាក់ទងដល់កម្មសិទ្ធិបញ្ញា រវាងក្រសួងពាក់ព័ន្ធ
- សហការជំរុញការរៀបចំសេចក្តីព្រាងច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា និងក្នុងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា
- ទទួល និង ប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធ នឹង វិស័យកម្មសិទ្ធិបញ្ញា ពីបណ្តាប្រទេស និង អង្គការអន្តរជាតិនានា
- សហការជាមួយក្រសួងពាក់ព័ន្ធ ផ្សព្វផ្សាយច្បាប់ និង បទប្បញ្ញត្តិនានា ព្រមទាំងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា ដល់មហាជន មន្ត្រីអនុវត្តច្បាប់ និង សិស្ស និស្សិតតាមគ្រឹះស្ថានអប់រំសិក្សា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ស្ថាប័នតុលាការ ដើម្បីទប់ស្កាត់ និងបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា
- សហការសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និង អនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដើម្បីពិចារណាអំពីអត្ថប្រយោជន៍ ចំណុចខ្លាំង ចំណុចខ្សោយមុននឹងរាយការណ៍សុំការយល់ព្រមចូលជាសមាជិកពីប្រមុខរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល យ៉ាងតិច១ឆ្នាំម្តង និងតាមដំណាក់កាលនីមួយៗ។

**មាត្រា ៥. –**

សមាជិកនៃ គ.ក.ប ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន។

គ.ក.ប មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងពាណិជ្ជកម្ម ដើម្បីសម្រួលការងារ។

## មាត្រា ៦. –

គ.ក.ប មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម÷

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ប្រធាន
- មន្ត្រីបច្ចេកទេស នៃក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា ៣ សមាជិក

លេខាធិការដ្ឋាន គ.ក.ប មានទីតាំងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម និង អាចប្រើប្រាស់មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ជាជំនួយការ តាមការចាំបាច់។

## មាត្រា ៧. –

គ.ក.ប មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់ក្រសួងពាណិជ្ជកម្ម។ ប្រភពធនធាន និង ថវិការបស់ គ.ក.ប រួមមាន÷

- ថវិកាជាតិ
- ហិរញ្ញប្បទានសហប្រតិបត្តិការ ពីក្នុង និង ក្រៅប្រទេស ដែលផ្តល់ដោយអង្គការ អន្តរជាតិ និង ដៃគូអភិវឌ្ឍន៍នានា។

# ជំពូកទី ៣

# អវសានប្បញ្ញត្តិ

## មាត្រា ៨. –

សេចក្តីសម្រេចលេខ ១៦ សសរ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា និង បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

## មាត្រា ៩. –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ